**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ២៧ សលរ**

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តី

## នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងឱកាសទិវាប្រជាជនពិភពលោកលើកទី៣០ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩

- សូមក្រាបថ្វាយបង្គំ សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី
- ជនរួមជាតិជាទីស្រឡាញ់រាប់អាន

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ មានសេចក្តីសោមនស្សរីករាយ សូមថ្លែងទៅកាន់សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិទាំងអស់ថា ប្រជាជាតិកម្ពុជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាមួយប្រជាជាតិទូទាំងពិភពលោកក្នុងការប្រារព្ធ"**ទិវាប្រជាជនពិភពលោកលើកទី៣០**" ក្រោមប្រធានបទ"**ខួប២៥ឆ្នាំនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ** (25 years of the International Conference on Population and Development (ICPD)"។ ប្រធានបទនេះ ពិតជាមានអត្ថន័យធំធេង ដែលឆ្លុះបញ្ចាំងអំពីសមិទ្ធផលសំខាន់ៗដែលប្រជាជាតិនីមួយៗសម្រេចបានក្នុងរយៈពេល២៥ឆ្នាំនៃការអនុវត្តផែនការសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ នៅទីក្រុងគែរ ប្រទេសអេហ្ស៊ីប(Cairo, Egypt) ឆ្នាំ១៩៩៤ ដែលសន្និសីទនេះបានទទួលស្គាល់អំពីទំនាក់ទំនងទៅវិញទៅមករវាងប្រជាជននិងការអភិវឌ្ឍ និងអំពាវនាវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ចំពោះការផ្តល់ភាពអង់អាចដល់ស្ត្រី ការលើកកម្ពស់សុខភាពបន្តពូជនិងសិទ្ធិរបស់ស្ត្រី និងការដាក់បញ្ចូលបញ្ហានេះក្នុងការអភិវឌ្ឍជាតិ តំបន់ និងសកល។

ក្នុងនាមកម្ពុជា ជាប្រទេសហត្ថលេខីមួយក្នុងចំណោមប្រទេសចំនួន១៧៩ ដែលបានចុះហត្ថលេខាទទួលយកផែនការសកម្មភាពនៃសន្និសីទនេះមកអនុវត្ត កម្ពុជាបាននិងកំពុងប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការអនុវត្ត

## ១. កំណើនប្រជាជន និងសុខភាពបន្តពូជ

ប្រជាជនកម្ពុជា មានការកើនឡើងពី ចំនួន១១ លាននាក់ ក្នុងឆ្នាំ១៩៩៨ ដល់ជិត ១៦ លាននាក់ ក្នុងឆ្នាំ២០១៧ ហើយកំពុងមានបម្រែបម្រួលប្រជាសាស្ត្រមួយល្អប្រសើរដល់ការអភិវឌ្ឍ ដោយរចនាសម្ព័ន្ធអាយុប្រជាជនកម្ពុជានាពេលបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលភាគលាភប្រជាសាស្ត្រដ៏មានសក្តានុពលសេដ្ឋកិច្ច ដោយសារចំនួនច្រើនលើសលប់នៃប្រជាជនក្នុងវ័យធ្វើការ។ រយៈពេល២៥ឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាបានទទួលនូវការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការធានាលទ្ធភាពទទួលបានសុខភាពបន្តពូជសម្រាប់ស្ត្រី យុវវ័យ និងគូស្វាមីភរិយា។ ចាប់ពីទសវត្សឆ្នាំ២០០០មក អត្រាមរណភាពមាតាបានធ្លាក់ចុះយ៉ាងគំហុកពី៤៣៧នាក់ ក្នុងចំណោមទារកកើតរស់១០០.០០០នាក់ នៅឆ្នាំ២០០០ ដល់១៧០នាក់ នៅឆ្នាំ២០១៤ ហើយនឹងបន្តធ្លាក់ចុះដល់៦៥នាក់ នៅឆ្នាំ២០២០។ អត្រាមរណភាពកុមារក្រោម៥ឆ្នាំ បានថយចុះពី១២៥នាក់ មក៣៥នាក់ ក្នុង១.០០០កំណើតរស់ ក្នុងរវាងឆ្នាំ២០០០ និងឆ្នាំ២០១៤ ហើយក្នុងឆ្នាំដូចគ្នានេះដែរ ភាគរយនៃស្ត្រីរៀបការដែលមិនបានទទួលផែនការគ្រួសារបានធ្លាក់ចុះពី៣២,៦% ដល់១២,៥% ។

ការប្រើប្រាស់មធ្យោបាយពន្យារកំណើតក្នុងការរៀបចំផែនការគ្រួសារនៅកម្ពុជា បានរីកសាយភាយនៅទូទាំងប្រទេស ហើយចំណេះដឹងនៃការការពារការឆ្លងមេរោគអេដស៍ក្នុងចំណោមយុវវ័យបានកើនឡើងគួរឱ្យកត់សម្គាល់។ លទ្ធភាពមានកូនរបស់ស្ត្រីបានថយចុះពី៥កំណើត ក្នុងស្ត្រីម្នាក់ នៅឆ្នាំ១៩៩៤ មកត្រឹម ២,៧កំណើត នៅឆ្នាំ២០១៤។

ការធ្លាក់ចុះនៃអត្រាមរណៈទាំងនេះ បាននាំឱ្យអាយុសង្ឃឹមរស់កើនឡើង។ អាយុសង្ឃឹមរស់របស់ប្រជាជនកម្ពុជា បានកើនពី៥៥ឆ្នាំ នៅឆ្នាំ១៩៩៥ ដល់៦១ នៅក្នុងឆ្នាំ២០១០ (ក្នុងនោះអាយុបុរសកើនឡើងពី ៥៤ឆ្នាំ ទៅ៦០ឆ្នាំ និងអាយុស្ត្រី កើនពី៥៧ឆ្នាំ ទៅ៦៣ឆ្នាំ)។ មកដល់ឆ្នាំ២០១៨ អាយុសង្ឃឹមរស់របស់បុរសកើនដល់៦៨ឆ្នាំ និងអាយុស្ត្រីកើនដល់៧២ឆ្នាំ។

## ២. កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ

កំណើនសេដ្ឋកិច្ចដែលបានរៀបរាប់ខាងលើ បានជំរុញកំណើនផលិតផលក្នុងស្រុកសម្រាប់ប្រជាជនម្នាក់ៗ ពី៧៣៨ដុល្លារ នៅឆ្នាំ២០០៨ ដល់១.៥៤៨ដុល្លារ នៅឆ្នាំ២០១៨ ហើយអត្រាភាពក្រីក្រនៅកម្ពុជាបានថយចុះពី៤៧% នៅឆ្នាំ២០០៧ មកនៅត្រឹមរង្វង់ប្រមាណ១៣,៥% នៅឆ្នាំ២០១៤។ កម្មវិធីមូលនិធិសមធម៌សុខភាពជាតិ តាមរយៈការអនុវត្តកម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាកត្តាសំខាន់មួយដែលរួមចំណែកក្នុងការសម្រេចបានលទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ។

## ៣. នគរូបនីយកម្ម និងទេសន្តប្រវេសន៍

យើងសង្កេតឃើញថា នគរូបនីយកម្មនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ចាប់តាំងពីដើមទសវត្សរ៍៩០ មក គឺបានកើនពី ១៥,៧% នៅឆ្នាំ១៩៩៨ ដល់ ១៩,៥% នៅឆ្នាំ២០០៨ និងដល់២១,៤% នៅឆ្នាំ២០១៣ ហើយអត្រានេះរំពឹងថានឹងបន្តកើនឡើងយ៉ាងឆាប់រហ័សនាពេលអនាគត។

កំណើនទេសន្តប្រវេសន៍នៅរាជធានីភ្នំពេញមានការកើនឡើងខ្លាំង ដោយសារទេសន្តប្រវេសន៍ពីតំបន់ជនបទមករាជធានីភ្នំពេញ ដែលធ្វើឱ្យចំនួនប្រជាជននៅភ្នំពេញមានការកើនឡើងជាងទ្វេដងក្នុងរយៈពេល ១០ឆ្នាំ គឺកើនពី៥៧០.០០០នាក់ នៅឆ្នាំ១៩៩៨ ដល់១ ៦៨៨ ០៤៤នាក់ នៅឆ្នាំ២០១៣ និងត្រូវបានព្យាករណ៍ថាកើនឡើងដល់២ ៤៥០ ៧០០នាក់ នៅឆ្នាំ២០៣០។ ការកើនឡើងយ៉ាងគំហុកដូច្នេះ ទាមទារឱ្យ មានការរៀបចំផែនការទីក្រុងច្បាស់លាស់ដើម្បីបញ្ចៀសកំណើននគរូបនីយកម្មដោយចៃដន្យ។

## ៤. ប្រជាជន និងការអប់រំ

អត្រាអក្ខរកម្មរបស់មនុស្សពេញវ័យ(ចាប់ពី១៥ឆ្នាំឡើងទៅ) នៅកម្ពុជានៅឆ្នាំ២០០៨ មានចំនួន ៧៧,៦% កើនដល់៨២,៥% នៅឆ្នាំ២០១៨។ អត្រារួមនៃការសិក្សាបានកើនឡើងគួរឱ្យកត់សម្គាល់នៅគ្រប់កម្រិតសិក្សានិងគម្លាតយេនឌ័រនៃអត្រារួមនៃការសិក្សាត្រូវបានលុបបំបាត់ទាំងស្រុង។

## ៥. កិច្ចការពារជនងាយរងគ្រោះ

កម្ពុជាបាននិងកំពុងអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ ដើម្បីបង្កើតឱ្យមានផែនការយុទ្ធសាស្ត្រដើម្បីសុវត្ថិភាពប្រាក់ចំណូល កាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ព្រមទាំងបង្កើនសុខុមាលភាពរបស់ប្រជាជន និងពង្រឹងសាមគ្គីភាពក្នុងសង្គម។

## ៦. ប្រជាជនវ័យចាស់

យើងសង្កេតឃើញថា សន្ទស្សន៍ភាពចាស់នៅកម្ពុជាបានកើនឡើងយឺតៗ នៅចន្លោះឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ ប៉ុន្តែកំណើននេះត្រូវបានព្យាករណ៍ថា នឹងកើនឡើងយ៉ាងឆាប់រហ័សនាទសវត្សរ៍ខាងមុខ។ តាមការព្យាករណ៍ ប្រជាជនវ័យចាស់មាននិន្នាការកើនឡើងប្រមាណពី៧,២% នៅឆ្នាំ២០១៥ ដល់១១% នៅឆ្នាំ២០៣០។ ឆ្លើយតបទៅនឹងបញ្ហាកំណើនប្រជាជនវ័យចាស់នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់២០១៧-២០៣០ សំដៅគាំទ្រនិងដោះស្រាយបញ្ហាមនុស្សវ័យចាស់ ដោយយកចិត្តទុកដាក់ទៅលើផលប៉ះពាល់នៃការប្រែប្រួលប្រជាសាស្ត្រនិងការអភិវឌ្ឍ ដោយឈរលើទស្សនវិស័យថាមនុស្សវ័យចាស់អាចចូលរួមដោយសេរីនិងសេចក្តីថ្លៃថ្នូរ ក្នុងសកម្មភាពគ្រួសារ សហគមន៍ សេដ្ឋកិច្ច សាសនា និងនយោបាយ តាមបំណងប្រាថ្នារបស់ពួកគាត់។

## ៧.	ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

កម្ពុជាបាននិងកំពុងបន្តពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី តាមរយៈការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងគ្រប់គោលនយោបាយ ផែនការជាតិ កម្មវិធីគម្រោងនានា ព្រមទាំងបន្តអនុវត្តអនុសញ្ញាស្តីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងនារីភេទ ការរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រនិងការបញ្ជ្រាបយេនឌ័រនៅគ្រប់ក្រសួងស្ថាប័ន និងថ្នាក់ក្រោមជាតិ។

ចំនួនស្ត្រីកម្ពុជា ជាថ្នាក់ដឹកនាំក្នុងអង្គនីតិប្រតិបត្តិមានការកើនឡើងជាលំដាប់ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៨។ នៅឆ្នាំ១៩៩៣ កម្ពុជាមានស្ត្រីតែពីររូបប៉ុណ្ណោះដែលមានតំណែងជាអនុរដ្ឋលេខាធិការ មកដល់ឆ្នាំ២០១៨ កម្ពុជាមានស្ត្រី ចំនួន៦១រូបជាអនុរដ្ឋលេខាធិការ ៤០រូបជារដ្ឋលេខាធិការ ៣រូបជារដ្ឋមន្ត្រី និង១រូបជាឧបនាយករដ្ឋមន្ត្រី។

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ

ទោះបីជារាជរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធផលដ៏ធំធេងគួរឱ្យកត់សម្គាល់ដូចបានលើកឡើងខាងលើនេះក្តី ក៏លទ្ធផលនៅមិនទាន់ឈានដល់កម្រិតដែលយើងចង់បាននៅឡើយ ជាពិសេសបញ្ហាប្រឈមចម្បងៗនៅតែមាន ដូចជាផ្នែកគុណភាពសេវាជាដើម។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ គ្រប់ផ្នែក គ្រប់វិស័យ និងគ្រប់ថ្នាក់ ព្រមទាំងប្រជាជនគ្រប់រូប បន្តគាំទ្រ និងចូលរួមដោះស្រាយបញ្ហាប្រជាជននិងការអភិវឌ្ឍ ប្រកបដោយគុណភាព និងប្តេជ្ញាចិត្តក្នុងការឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពដោយ "គ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល" (Leaving no one behind)។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជានឹងចូលរួមក្នុងសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ ដែលនឹងប្រារព្ធធ្វើនៅទីក្រុងណៃរ៉ូប៊ីនៃសាធារណរដ្ឋកេនយ៉ា នាខែវិច្ឆិកា ឆ្នាំនេះ ដែលជាខួបលើកទី២៥ឆ្នាំនៃការអនុវត្តផែនការសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ។ យោងលើសមិទ្ធផល២៥ឆ្នាំ នៃការអនុវត្តផែនការសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជនិងការអភិវឌ្ឍនៅកម្ពុជា រាជរដ្ឋាភិបាល សូមធ្វើការបញ្ជាក់ឡើងវិញថា កម្ពុជាបន្តប្តេជ្ញាចិត្តអនុវត្តន៍ទាំងស្រុងនិងប្រកបដោយប្រសិទ្ធភាព នូវផែនការសកម្មភាពនេះនិងទទួលស្គាល់អំពីការពាក់ព័ន្ធនៃផែនការសកម្មភាពនេះទៅនឹងគោលបំណង និងគោលដៅនៃរបៀបវារៈការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០។

ជាមួយនឹងការអបអរសាទរខួប២៥ឆ្នាំនៃការអនុវត្តផែនការសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ ខ្ញុំព្រះករុណា ខ្ញុំសូមឆ្លៀតយកឱកាសនេះផងដែរ អបអរខួប២៥ឆ្នាំ និងសូមអរគុណដល់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA) ដែលបានប្រតិបត្តិការនៅលើទឹកដីកម្ពុជានិងសូមវាយតម្លៃខ្ពស់ជូនចំពោះអង្គការសហប្រជាជាតិនិងដៃគូអភិវឌ្ឍន៍នានា ដែលបានបន្តកិច្ចសហការនិងគាំទ្រដល់ប្រទេសនិងប្រជាជនកម្ពុជាក្នុងរយៈពេលកន្លងមក។ ខ្ញុំព្រះករុណា ខ្ញុំសង្ឃឹមយ៉ាងមុតមាំចំពោះសុឆន្ទៈនៃការពង្រឹង

និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ កាន់តែសកម្មខ្លាំងឡើងថែមទៀត ដើម្បីគោលដៅរួមរបស់យើងទាំងអស់គ្នា គឺៈការកសាងពិភពលោកមួយ ដែលគ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោលៈ។

ខ្ញុំព្រះករុណា ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនស្នាក់ការកណ្តាល ដែលបានផ្តល់"ជ័យលាភីនៃការធ្វើឱ្យមានភាពប្រសើរឡើង" ឬ"Champion of Change" ដល់បុគ្គលឆ្នើមចំនួន១៥រូប នៅក្នុងពិភពលោក ដែលបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ ដែលក្នុងចំណោមបុគ្គលឆ្នើមទាំង១៥រូបនោះ គឺមានមន្ត្រីជាន់ខ្ពស់មួយរូបរបស់ក្រសួងផែនការនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

ជាទីបញ្ចប់នេះ ខ្ញុំព្រះករុណា ខ្ញុំសូមប្រគេនពរនិងសូមជូនពរដល់ សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

សូមអរព្រះគុណនិងសូមអរគុណ!

ថ្ងៃចន្ទ ១៤ កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**